ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៤៣៥ MIH / 2014

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.**_

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់។

**ប្រការ២.**_

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម ៖

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់
- រៀបចំតួនាទី និងភារកិច្ចរបស់ការិយាល័យនានា នៃនាយកដ្ឋានវាយតម្លៃទទួលស្គាល់
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារវាយតម្លៃទទួលស្គាល់របស់ក្រសួង។

**ប្រការ៣.**_

នាយកដ្ឋានវាយតម្លៃទទួលស្គាល់មានមុខងារ និងភារកិច្ចដូចតទៅ ៖

- ជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម លើការងារវាយតម្លៃទទួលស្គាល់

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា



ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

- គ្រប់គ្រង ជំរុញ និងអភិវឌ្ឍការងារវាយតម្លៃទទួលស្គាល់ឱ្យសមស្របទៅនឹងតម្រូវការជាក់ស្តែងក្នុងតំបន់ និងអន្តរជាតិ
- រៀបចំលិខិតបទដ្ឋានគតិយុត្តិ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការវាយតម្លៃទទួលស្គាល់
- រៀបចំកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើការងារវាយតម្លៃទទួលស្គាល់ ជាមួយបណ្តាប្រទេសនានា
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម រូបវន្តបុគ្គលណាមួយដែលមានលក្ខណៈសម្បត្តិ ដើម្បីអនុវត្តការវាយតម្លៃភាពអនុលោម និងសេវាកម្មវាយតម្លៃភាពអនុលោមនានា
- រៀបចំកិច្ចព្រមព្រៀង ឬកិច្ចសន្យាដល់អង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ ធ្វើតេស្ត ឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម រូបវន្តបុគ្គលណាមួយដែលមានលក្ខណៈសម្បត្តិ ដើម្បីអនុវត្តការវាយតម្លៃភាពអនុលោម និងសេវាកម្មវាយតម្លៃភាពអនុលោមនានា ដែលពាក់ព័ន្ធនឹងការអនុវត្តន៍តាមការតម្រូវនៃប្រព័ន្ធចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី
- ធ្វើសវនកម្មអង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម រូបវន្តបុគ្គលណាមួយដែលមានលក្ខណៈសម្បត្តិ ដើម្បីអនុវត្តការវាយតម្លៃភាពអនុលោម និងសេវាកម្មវាយតម្លៃភាពអនុលោមនានា ដែលបានស្នើសុំ និងដែលបានទទួលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី
- ចុះបញ្ជីលើវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ដែលអង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារទទួលបានវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ពីអង្គភាពវាយតម្លៃទទួលស្គាល់ក្រៅប្រទេស
- ចុះបញ្ជីទំនិញនាំចេញនាំចូលដោយប្រើសញ្ញាវាយតម្លៃទទួលស្គាល់បានទទួលពីក្នុង និងក្រៅប្រទេស
- រៀបចំកិច្ចព្រមព្រៀងទទួលស្គាល់ជាមួយមន្ទីរពិសោធន៍ដែលទទួលបានវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ពីស្ថាប័នវាយតម្លៃទទួលស្គាល់ក្នុងតំបន់ ក៏ដូចជាអន្តរជាតិ
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ចូលជាសមាជិកស្ថាប័នវាយតម្លៃទទួលស្គាល់ក្នុងតំបន់ក៏ដូចជាអន្តរជាតិ
- ចូលរួមសហការជាមួយសមាគមក្នុង និងក្រៅប្រទេស អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានា ក្នុងការវាយតម្លៃទទួលស្គាល់និងចុះបញ្ជី និងរៀបចំអនុវត្តកិច្ចព្រមព្រៀងនានា
- រៀបចំកម្មវិធីបណ្តុះបណ្តាល និងផ្សព្វផ្សាយការងារវាយតម្លៃទទួលស្គាល់
- តាមដាន និងអង្កេតលើការប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ដែលគ្រប់ស្ថាប័ន ឬអង្គភាពវាយតម្លៃភាពអនុលោមបានទទួលពីក្នុង និងក្រៅប្រទេស
- ជំរុញការងារបញ្ញាបយេនឌ័រ
- បូកសរុបរបាយការណ៍វាយតម្លៃលទ្ធផលការងារ និងអភិវឌ្ឍវិស័យវាយតម្លៃទទួលស្គាល់
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធានស្ថាប័នប្រគល់ជូន។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

**ប្រការ៤._**

នាយកដ្ឋានវាយតម្លៃទទួលស្គាល់ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ៥._**

នាយកដ្ឋានវាយតម្លៃទទួលស្គាល់មានការិយាល័យក្រោមឱវាទចំនួន៤ ដូចខាងក្រោម ៖

- ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារផលិតផល
- ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារប្រព័ន្ធគ្រប់គ្រង
- ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារជាតិ និងអន្តរជាតិ
- ការិយាល័យទំនាក់ទំនង។

**ប្រការ៦._**

ការិយាល័យជំនាញនីមួយៗដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ៧._**

តួនាទី និងភារកិច្ចរបស់ការិយាល័យជំនាញនីមួយៗ មានដូចតទៅ ៖

**១- ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារផលិតផល**

**ក- តួនាទី**

ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារផលិតផល ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីដល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារផលិតផល។

**ខ- ភារកិច្ច**

ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារផលិតផល មានភារកិច្ចដូចតទៅ ៖

- គ្រប់គ្រងលិខិតចេញ ចូលគ្រប់ប្រភេទ និងតម្កល់ឯកសារ
- រៀបចំផែនការសកម្មភាព និងផែនការថវិការបស់នាយកដ្ឋាន
- រៀបចំតម្កល់ឯកសារច្បាប់ អនុក្រឹត្យ គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា
- រៀបចំធ្វើបញ្ជីកត់ត្រាអំពីវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ទាំងឡាយ ដែលបានរៀបចំដោយនាយកដ្ឋាន
- ចុះបញ្ជីទំនិញនាំចេញនាំចូលដោយប្រើសញ្ញាវាយតម្លៃទទួលស្គាល់
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ចេញវិញ្ញាបនបត្រចុះបញ្ជីដល់អង្គភាពវាយតម្លៃភាពអនុលោមផលិតផលជាតិគ្រប់កម្រិតខ្នាតវិនិយោគ
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ដល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារផលិតផលកម្រិតស្តង់ដារតំបន់ និងអន្តរជាតិ
- រៀបចំកិច្ចព្រមព្រៀង ឬកិច្ចសន្យាដល់អង្គភាពវាយតម្លៃភាពអនុលោមផលិតផលថ្នាក់ជាតិគ្រប់កម្រិតខ្នាតវិនិយោគ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

- រៀបចំកិច្ចព្រមព្រៀង ឬកិច្ចសន្យាដល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារផលិតផល កម្រិតស្តង់ដារតំបន់ និងអន្តរជាតិ
- ជ្រើសរើសនកម្មអង្គភាពវាយតម្លៃភាពអនុលោមផលិតផលថ្នាក់ជាតិគ្រប់កម្រិតខ្នាតវិនិយោគ និងកម្រិតស្តង់ដារតំបន់ និងអន្តរជាតិ
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលវិញ្ញាបនបត្រចុះបញ្ជីដល់អង្គភាពវាយតម្លៃភាពអនុលោមផលិតផលថ្នាក់ជាតិគ្រប់កម្រិតខ្នាតវិនិយោគ ឬវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់កម្រិតស្តង់ដារតំបន់ និងអន្តរជាតិ
- តាមដាន និងពិនិត្យអង្កេតលើការប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីដែលអង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារផលិតផលទទួលបាន
- ចុះបញ្ជីវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ដែលអង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារទទួលបានពីក្នុង និងក្រៅប្រទេស
- ទទួលបន្ទុកសហការ និងចូលរួមក្នុងគណកម្មការ ក្រុមការងារជាតិ និងអន្តរជាតិ ទាក់ទិនជាមួយការវាយតម្លៃទទួលស្គាល់លើអង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារផលិតផល
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

## ២- ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារប្រព័ន្ធគ្រប់គ្រង

### ក- តួនាទី

ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារប្រព័ន្ធគ្រប់គ្រង ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោមប្រព័ន្ធគ្រប់គ្រង។

### ខ- ភារកិច្ច

ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារប្រព័ន្ធគ្រប់គ្រង មានភារកិច្ចដូចតទៅ ៖

- រៀបចំ និងគ្រប់គ្រងការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាល អភិវឌ្ឍធនធានមនុស្ស
- បូកសរុបរបាយការណ៍វាយតម្លៃលទ្ធផលការងារ និងវឌ្ឍនភាពការងារ
- គ្រប់គ្រងសារពើភ័ណ្ឌ និងផ្គត់ផ្គង់សម្ភារៈការិយាល័យនៅក្នុងនាយកដ្ឋាន
- ចុះបញ្ជីទំនិញនាំចេញនាំចូលដោយប្រើសញ្ញាវាយតម្លៃទទួលស្គាល់
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ចេញវិញ្ញាបនបត្រចុះបញ្ជីដល់អង្គភាពវាយតម្លៃភាពអនុលោមប្រព័ន្ធគ្រប់គ្រងថ្នាក់ជាតិគ្រប់កម្រិតខ្នាតវិនិយោគ
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ដល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារប្រព័ន្ធគ្រប់គ្រង (ISO 9001, ISO 14001, ISO 22000, HACCP, GMP, ISO 18000, ISO 50001 ។ល។) តាមកម្រិតស្តង់ដារតំបន់ និងអន្តរជាតិ
- រៀបចំកិច្ចព្រមព្រៀង ឬកិច្ចសន្យាដល់អង្គភាពវាយតម្លៃភាពអនុលោមប្រព័ន្ធគ្រប់គ្រងថ្នាក់ជាតិគ្រប់កម្រិតខ្នាតវិនិយោគ និងកម្រិតស្តង់ដារតំបន់ និងអន្តរជាតិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

- ធ្វើសវនកម្មអង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារប្រព័ន្ធគ្រប់គ្រងគ្រប់កម្រិតខ្នាតវិនិយោគ និងកម្រិតស្តង់ដារតំបន់ និងអន្តរជាតិ
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីដល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារប្រព័ន្ធគ្រប់គ្រង
- ពិនិត្យ តាមដាន និង អង្កេតលើការប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីដែលទទួលបានពីក្នុង និងក្រៅប្រទេស
- ចុះបញ្ជីវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ដែលអង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារប្រព័ន្ធគ្រប់គ្រងទទួលបានពីក្នុង និងក្រៅប្រទេស
- ទទួលបន្ទុកចូលរួមក្នុងគណៈកម្មការ ក្រុមការងារជាតិ និងអន្តរជាតិទាក់ទិនជាមួយការវាយតម្លៃទទួលស្គាល់លើអង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារប្រព័ន្ធគ្រប់គ្រង
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

## ៣- ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារជាតិ និងអន្តរជាតិ

### ក- តួនាទី

ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារជាតិ និងអន្តរជាតិ ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីអង្គភាពមន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អធិការកិច្ច និងសេវាកម្មវាយតម្លៃភាពអនុលោមនានា។ល។

### ខ- ភារកិច្ច

ការិយាល័យវាយតម្លៃទទួលស្គាល់អង្គភាពវាយតម្លៃភាពអនុលោមស្តង់ដារជាតិ និងអន្តរជាតិ មានភារកិច្ចដូចតទៅ ៖

- រៀបចំកិច្ចព្រមព្រៀងទទួលស្គាល់គ្នាជាមួយ មន្ទីរពិសោធន៍ដែលបានការទទួលស្គាល់ពីស្ថាប័នវាយតម្លៃទទួលស្គាល់ជាតិ និងអន្តរជាតិ
- ចុះបញ្ជីទំនិញនាំចេញនាំចូលដោយប្រើសញ្ញាវាយតម្លៃទទួលស្គាល់
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ការចេញវិញ្ញាបនបត្រចុះបញ្ជីដល់អង្គភាពមន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អធិការកិច្ច និងសេវាកម្មវាយតម្លៃភាពអនុលោមនានា។ល។
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ដល់អង្គភាពមន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អធិការកិច្ច និងសេវាកម្មវាយតម្លៃភាពអនុលោមនានា។ល។ តាមកម្រិត ស្តង់ដារតំបន់ និងអន្តរជាតិ
- រៀបចំកិច្ចព្រមព្រៀង ឬកិច្ចសន្យាដល់អង្គភាពមន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អធិការកិច្ច និងសេវាកម្មវាយតម្លៃភាពអនុលោមនានា។ល។
- ធ្វើសវនកម្មអង្គភាពមន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អធិការកិច្ច និងសេវាកម្មវាយតម្លៃភាពអនុលោមនានា។ល។ ដែលទទួលបានវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី


ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

- រៀបចំបែបបទ និងនីតិវិធីសម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោល វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី អង្គភាពមន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អធិការកិច្ច និងសេវាកម្មវាយតម្លៃភាពអនុលោមនានា។ល។
- ពិនិត្យ តាមដាន និងអង្កេតលើការប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីដែលទទួលបានពីក្នុង និងក្រៅប្រទេស
- ចុះបញ្ជីវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ដែលអង្គភាពមន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អធិការកិច្ច និងសេវាកម្មវាយតម្លៃភាពអនុលោមនានា។ល។ ទទួលបានពីក្នុង និងក្រៅប្រទេស តាមស្តង់ដារតំបន់ និងអន្តរជាតិ
- ចូលរួមក្នុងគណកម្មការក្រុមការងារជាតិ និងអន្តរជាតិទាក់ទិននឹងការវាយតម្លៃទទួលស្គាល់លើអង្គភាពមន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អធិការកិច្ច និងសេវាកម្មវាយតម្លៃភាពអនុលោមនានា។ល។
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

## ៤- ការិយាល័យទំនាក់ទំនង

### ក- តួនាទី

ការិយាល័យទំនាក់ទំនង ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារសហប្រតិបត្តិការ និងអភិវឌ្ឍការវាយតម្លៃទទួលស្គាល់។

### ខ- ភារកិច្ច

ការិយាល័យទំនាក់ទំនង មានភារកិច្ចដូចតទៅ ៖

- គ្រប់គ្រងការងារបុគ្គលិក មន្ត្រីរាជការផ្ទៃក្នុងនាយកដ្ឋាន
- រៀបចំពិធីបដិសណ្ឋារកិច្ច និងកិច្ចប្រជុំរបស់នាយកដ្ឋាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តិ និងនីតិវិធីបង្កើតក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ និងគណៈកម្មការវាយតម្លៃទទួលស្គាល់គ្រប់ជំនាញ
- រៀបចំបែបបទ និងនីតិវិធីបង្កើតរូបសញ្ញារបស់អង្គភាព និងសញ្ញាវាយតម្លៃទទួលស្គាល់
- ចុះបញ្ជីបុគ្គលវាយតម្លៃទទួលស្គាល់ជាតិ និងអន្តរជាតិ
- បំពេញតួនាទីជាការិយាល័យកណ្តាលរវាងស្ថាប័នស្នើសុំ និងអង្គភាពវាយតម្លៃទទួលស្គាល់ជាដៃគូអន្តរជាតិ
- សម្របសម្រួលរាល់ការងាររវាងអតិថិជនដែលស្នើសុំការវាយតម្លៃទទួលស្គាល់
- ជំរុញ និងអភិវឌ្ឍការងារវាយតម្លៃទទួលស្គាល់ឱ្យសមស្របទៅនឹងតម្រូវការជាក់ស្តែងក្នុងតំបន់ និងអន្តរជាតិ
- រៀបចំលិខិតបទដ្ឋានគតិយុត្តិនិងបទប្បញ្ញត្តិពាក់ព័ន្ធ នឹងការវាយតម្លៃទទួលស្គាល់
- រៀបចំបែបបទ និងនីតិវិធីដើម្បីចូលជាសមាជិកនៃស្ថាប័នវាយតម្លៃទទួលស្គាល់តំបន់នានា និងអន្តរជាតិ
- ចូលរួមសហការជាមួយសមាគម អង្គភាពវាយតម្លៃទទួលស្គាល់ក្នុង និងក្រៅប្រទេស



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

- រៀបចំកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកស្តីពីការងារវាយតម្លៃទទួលស្គាល់
- សហការជាមួយសមាគម អង្គការអន្តរជាតិនានា ក្នុងការវាយតម្លៃទទួលស្គាល់ និងចុះបញ្ជី
- ធ្វើការផ្សព្វផ្សាយព័ត៌មានថ្មីៗ ដែលទទួលបាន ពាក់ព័ន្ធនឹងការវាយតម្លៃទទួលស្គាល់ដល់ស្ថាប័នពាក់ព័ន្ធក្នុង និងក្រៅប្រទេស
- ជំរុញការងារបញ្ញាបយេនឌ័រ
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**ប្រការ៨._**

ការបែងចែកភារកិច្ចរបស់មន្ត្រីនាយកដ្ឋានវាយតម្លៃទទួលស្គាល់ ជាសមត្ថកិច្ចរបស់ប្រធាននាយកដ្ឋាន។

**ប្រការ៩._**

ប្រកាសលេខ ១១០៧ ឧរថ.វសក.ប្រក ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានបញ្ញត្តកម្ម និងវាយតម្លៃទទួលស្គាល់ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ និងគ្រប់អង្គភាពក្រោមឱវាទក្រសួងត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល</u> ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

*« ដើម្បីជូនជ្រាប »*

- ដូចប្រការ១០

*« ដើម្បីអនុវត្ត »*

- ឯកសារ-កាលប្បវត្តិ



**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

**ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី**
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

# អង្គការលេខរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់

ភ្ជាប់ជាឯកសារឧបសម្ព័ន្ធនៃប្រកាសលេខ ៤៣៥ MIH / 2014 ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៤

